សាលាកប័ត្រព័ត៌មាន៖ កម្រងអត្ថបទស្តាប័ន៖ ស្តាប័នជាតិសិទ្ធិមនុស្សនៅកម្ពុជា

ស្តាប័ន៖ គណៈកម្មការសិទ្ធិមនុស្សនៃរដ្ឋសភា ("គ.ក.ស.រ") គណៈកម្មការសិទ្ធិមនុស្សនៃព្រឹទ្ធសភា ("គ.ក.ស.ព") និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ("គ.ក.ស.ក") តទៅនេះហៅថា "ស្តាប័នជាតិសិទ្ធិមនុស្ស"។

រូបភាពរួម៖ ស្តាប័នជាតិសិទ្ធិមនុស្សដែលតំណាងឲ្យយន្តការដ៏មានសក្តានុពលក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") បរាជ័យក្នុងការបង្ហាញថាស្តាប័នខ្លួនមានស្វ័យភាពគ្រប់គ្រាន់ដើម្បីធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជា ("រ.រ.ក") ធ្វើការពិចារណាចំពោះបញ្ហាសិទ្ធិមនុស្សនានា។

សេចក្តីផ្តើម

សាលាកប័ត្រព័ត៌មាននេះគូសបញ្ជាក់អំពីកិច្ចការរបស់ស្តាប័នជាតិសិទ្ធិមនុស្ស - "គ.ក.ស.រ" "គ.ក.ស.ព" និង("គ.ក.ស.ក") - មុនការអំពាវនាវឲ្យបង្កើតស្តាប័នជាតិសិទ្ធិមនុស្សឯករាជ្យ ("ស.ជ.ស.ម")។ សាលាកប័ត្រព័ត៌មាននេះត្រូវបានចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

គណៈកម្មការសិទ្ធិមនុស្សនៃរដ្ឋសភា

រដ្ឋសភាដែលជាសភាជាន់ទាបនៃស្តាប័នសភាដែលមានពីរថ្នាក់របស់កម្ពុជាបែងចែកនូវគណៈកម្មការចំនួន៩ផ្សេងពីគ្នា ហើយដែលគណៈកម្មការនីមួយៗមានជំនាញ និងតួនាទីជាក់លាក់ផ្សេងៗរបស់ខ្លួន។ "គ.ក.ស.រ" គឺជាគណៈកម្មការមួយក្នុងនោះដែរ។ គោលបំណងរបស់គណៈកម្មការនេះបំពេញតួនាទីជាយន្តការ ដែលពលរដ្ឋគ្រប់រូបអាចលើកឡើងនូវបញ្ហាដែលជាក្តីបារម្ភ និងបណ្តឹងដែលពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្ស។ គណៈកម្មការនេះមានសមាសភាពសមាជិកចំនួន៧រូប ដែលគ្រប់រូបជាសមាជិកនៃរដ្ឋសភា។ សមាជិកភាគច្រើនលើសលុបនៃ "គ.ក.ស.រ" គឺមកពីគណៈបក្សប្រជាជនកម្ពុជា ("គ.ប.ក")។ ក្នុងនាមជាអ្នកតំណាងឲ្យប្រជាពលរដ្ឋ "គ.ក.ស.រ" ត្រូវមានភារៈកិច្ចទទួលខុសត្រូវចំពោះការលើកស្ទួយសិទ្ធិមនុស្ស និងដោះស្រាយសំណើ និងបណ្តឹងរបស់ប្រជាពលរដ្ឋដែលសិទ្ធិរបស់ពួកគាត់ត្រូវបានបំពានដោយរដ្ឋ ឬស្តាប័នរបស់រដ្ឋផ្សេងៗទៀត។ គណៈកម្មការនេះក៏មានមានតួនាទីជាស្តាប័នប្រឹក្សាយោបល់លើច្បាប់ដែលពាក់ព័ន្ធដល់ "រ.រ.ក" និងទទួលអាណត្តិក្នុងការលើកឡើងការយល់ដឹង និងការអប់រំ។ នៅក្នុងឆ្នាំ២០១១ សាស្ត្រាចារ្យ ស៊ូរយ៉ា ស៊ូប៊ីឌី អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ("អ.ស.ប") ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ("អ្នករាយការណ៍ពិសេស") បានរាយការណ៍ថា "គ.ក.ស.រ" បានទទួលពាក្យបណ្តឹងសរុបចំនួន ១.១៥៨ ពីសាធារណៈជននៅចន្លោះឆ្នាំ២០០៦ និង២០១០ ដែលភាគច្រើនគឺបណ្តឹងទាក់ទិននឹងវិវាទដីធ្លី ហើយលោកបន្ថែមទៀតថា "គ.ក.ស.រ" បានសរសេរលិខិតទៅកាន់ស្តាប័នផ្សេងៗរបស់រដ្ឋាភិបាលនៅក្នុង "ចំនួនដ៏ត្រឹមត្រូវ" នៃករណីវិវាទ។ ចំនួនសរុបនៃការឆ្លើយតបពីស្តាប័នផ្សេងៗរបស់រដ្ឋាភិបាលទទួលបានប្រហែលជា២៥០។ អ្នករាយការណ៍ពិសេសបានរាយការណ៍ទៀតថា "គ.ក.ស.រ" បានត្រួតពិនិត្យសេចក្តីព្រាងច្បាប់ផ្សេងៗជាច្រើនដែលពាក់ព័ន្ធនឹងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស។

គណៈកម្មការសិទ្ធិមនុស្សនៃព្រឹទ្ធសភា

ព្រឹទ្ធសភាដែលជាសភាជាន់ខ្ពស់នៃស្តាប័នសភាដែលមានពីរថ្នាក់របស់កម្ពុជាមានរចនាសម្ព័ន្ធគណៈកម្មការស្រដៀងគ្នានឹងរដ្ឋសភាដែរ ដែលមានទាំង "គ.ក.ស.ព"។ "គ.ក.ស.ព" មានសមាសភាពព្រឹទ្ធសមាជិក៥រូប ដែលអសនៈភាគច្រើនកាន់កាប់ដោយព្រឹទ្ធសមាជិកមកពី "គ.ប.ក"។ អនុលោមតាមសេចក្តីសម្រេចស្តីពីតួនាទី ភារៈកិច្ច និងសមត្ថភាពនៃគណៈកម្មការសិទ្ធិមនុស្ស ការទទួលពាក្យបណ្តឹង និងស៊ើបអង្កេតនៅក្នុងឆ្នាំ២០០៦ ("សេចក្តីសម្រេចឆ្នាំ២០០៦") តួនាទីដែលបានចែងរបស់ "គ.ក.ស.ព" គឺត្រូវលើកស្ទួយ និងការពារសិទ្ធិរស់រានដោយសេចក្តីថ្លៃថ្នូរ និងសមភាពចំពោះមុខច្បាប់របស់ពលរដ្ឋគ្រប់រូប ព្រមទាំងតាមដាន និងឃ្លាំមើលការអនុវត្តន៍សិទ្ធិមនុស្សនៅកម្ពុជា។ ភារៈកិច្ចរបស់"គ.ក.ស.ព" គឺត្រូវទទួលពាក្យបណ្តឹងពីគ្រប់បុគ្គលផ្តួចផ្តើមសេចក្តីព្រាងសំណើច្បាប់ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីសិទ្ធិមនុស្សដូចដែលបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតូបករណ៍អន្តរជាតិផ្សេងៗទៀត ហើយស៊ើបអង្កេតលើបណ្តឹងដែលធ្វើឡើងដោយសាធារណៈជន។ អ្នករាយការណ៍ពិសេសបានចាត់ទុកថា"គ.ក.ស.ព"បំពេញតួនាទីរបស់ខ្លួនមានប្រសិទ្ធភាពគ្រាន់បើជាង"គ.ក.ស.រ"បន្តិច ព្រមទាំងមានវិធានការទប់ទល់ និងជួនកាលចូលរួមនៅក្នុងការបេសកកម្ម "ស្វែងរកហេតុការពិត" ដែលស្ថិតក្នុងគំនិតផ្តួចផ្តើមផ្ទាល់របស់

ខ្លួន។ អ្នករាយការណ៍ពិសេសរាយការណ៍ថា"គ.ក.ស.ព" ទទួលបានពាក្យបណ្តឹងចំនួន៣០០នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ និងទទួលបានការឆ្លើយតបពីស្តាប័នរដ្ឋាភិបាលប្រហែលជា១០០ក្នុងចំណោមបណ្តឹងទាំងនោះ។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

"គ.ក.ស.ក"ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ដែលត្រូវបាន"រ.ដ.ក"ផ្តល់ភារៈកិច្ចក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងវិធាននៃច្បាប់នៅកម្ពុជា។ តួនាទីរបស់"គ.ក.ស.ក"គឺត្រូវស៊ើបអង្កេត និងដោះស្រាយបណ្តឹងទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស ប្រមូលព័ត៌មានទាក់ទិននឹងការអនុវត្តន៍សិទ្ធិមនុស្ស រៀបចំបង្កើតវគ្គបណ្តុះបណ្តាល និងចែករំលែកព័ត៌មានអំពីសិទ្ធិមនុស្ស។ "គ.ក.ស.ក"ក៏មានការទទួលខុសត្រូវផងដែរលើការរៀបចំរបាយការណ៍អំពីបញ្ហាសិទ្ធិមនុស្សសម្រាប់"អ.ស.ប"។

ប្រសិទ្ធភាពរបស់ស្តាប័នជាតិសិទ្ធិមនុស្សនៅកម្ពុជា

នៅខណៈដែលអត្ថិភាពនៃស្តាប័នជាតិសិទ្ធិមនុស្សនៅកម្ពុជាជារឿងសំខាន់ ជាការចាំបាច់ដែលស្តាប័នទាំងនេះមានតួនាទីច្រើនជាងស្តាប័នដែលគ្រាន់តែជានិមិត្តរូប និងត្រូវបំពេញតួនាទីយ៉ាងមានប្រសិទ្ធភាពពិតប្រាកដនៅក្នុងការលើកស្ទួយនិងការពារសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតស្តាប័នទាំងនេះឡើងមានបញ្ហាចោទជាច្រើនទាក់ទិននឹងឯករាជ្យភាព និងស្វ័យភាពរបស់ស្តាប័នក្នុងការធ្វើឲ្យ"រ.ក"ពិចារណានៅពេលដែលបញ្ហាសិទ្ធិមនុស្សធ្លាក់ទៅក្នុងកាតព្វកិច្ចរបស់ខ្លួនក្នុងការដោះស្រាយ។ យើងឃើញថាទាំង"គ.ក.ស.រ" និង"គ.ក.ស.ព" គឺជាគណៈកម្មការនៅក្នុងស្តាប័នរដ្ឋសភា និងព្រឹទ្ធសភារៀងៗខ្លួន គណៈកម្មការទាំងនេះមានតែសមាជិកភាពនៃអង្គនីតិបញ្ញត្តិប៉ុណ្ណោះ ហើយត្រូវបានជ្រើសរើសដោយសមាជិកនៃសភាសាមី ដែលអាចធ្វើឲ្យពួកគេងាយនឹងទទួលឥទ្ធិពលរដ្ឋាភិបាល។ ហេតុដូច្នេះគណៈបក្សគ្រប់គ្រងអំណាចនឹងតែងតែគ្រប់គ្រងលើ"គ.ក.ស.រ" និង"គ.ក.ស.ព"។ "គ.ក.ស.ក" ក៏ត្រូវបានគេចាត់ទុកថាស្ថិតក្រោមគំនាបរបស់ស្តាប័ននីតិប្រតិបត្តិផងដែរ។ ដោយសារការងាយទទួលរងនូវឥទ្ធិពលពីរដ្ឋាភិបាល ស្តាប័នទាំងអស់នេះមិនមានគោលជំហរជាម្ចាស់ការក្នុងការបំពេញភារៈកិច្ចរបស់ពួកគេឲ្យមានប្រសិទ្ធភាពបានឡើយ។ បន្ថែមលើនេះទៀត នៅខណៈដែល"គ.ក.ស.ព"ទទួលអាណត្តិតាមការកំណត់ដោយសេចក្តីសម្រេចឆ្នាំ២០០៦ តួនាទីរបស់"គ.ក. ស.រ" និង"គ.ក.ស.ក"មិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់នៅឡើយទេ។ មិនមានវិធាន ឬសេចក្តីណែនាំច្បាស់លាស់ដើម្បីគ្រប់គ្រងលើវិធីសាស្ត្រដែលពួកគេគួរតែបំពេញ ហេតុដូច្នេះយើងមិនអាចធ្វើការវាយតម្លៃថាតើស្តាប័នទាំងនេះកំពុងតែបំពេញតួនាទីរបស់ខ្លួនឬយ៉ាងណានោះទេ។ ស្តាប័នជាតិសិទ្ធិមនុស្សខ្វះខាតភាពច្បាស់លាស់ និងភាពងាយយល់នៃនីតិវិធី ហើយគ្មានស្តាប័នណាមួយមាននីតិវិធីច្បាស់លាស់សម្រាប់សាធារណៈជនតាមដាននៅពេលដែលខ្លួនដាក់ពាក្យបណ្តឹង។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

នៅខែកញ្ញា ឆ្នាំ២០០៦ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្តេជ្ញាថារដ្ឋាភិបាលរបស់គាត់នឹងបង្កើតស្តាប័នជាតិសិទ្ធិមនុស្សដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីស – ជាគោលការណ៍ដែលត្រូវបានអនុម័តដោយ"អ.ស.ប" និងទាក់ទិននឹងហានៈ និងមុខងារនៃស្តាប័នជាតិសម្រាប់លើកស្ទួយ និងការពារសិទ្ធិមនុស្ស។ ទោះជាយ៉ាងនេះក្តី មានការវិវឌ្ឍន៍ដ៏តិចតួចនៅក្នុងការបញ្ហានេះ និងកង្វះខាតឆន្ទៈនយោបាយ។ ដោយសារតែមានបញ្ហាកង្វះខាតដែលគួរឲ្យកត់សម្គាល់លើឯករាជ្យភាពនៃស្តាប័នជាតិសិទ្ធិមនុស្សដែលមានស្រាប់ "រ.ក"ត្រូវតែស្វែងរកឆន្ទៈនយោបាយ និងធ្វើការងារឆ្ពោះទៅបង្កើត("ស.ជ.ស.ម") ដែលមិនត្រឹមតែឯករាជ្យប៉ុណ្ណោះទេ តែថែមទាំងមានប្រព័ន្ធត្រឹមត្រូវ និងតម្លាភាពក្នុងការជ្រើសរើសសមាជិកភាពដោយផ្អែកតាមគោលការណ៍ពហុនិយម ធ្វើដូច្នេះទើបសមាជិកភាពតំណាងឲ្យសង្គមកម្ពុជាគ្រប់ផ្នែក។ ជាពិសេស ស្តាប័នបែបនេះត្រូវតែមានអាណត្តិទូលំទូលាយគ្របដណ្តប់លើការលើកស្ទួយ និងការពារសិទ្ធិមនុស្ស ដោយខ្លួនមានអំណាចច្បាស់លាស់ និងធនធានគ្រប់គ្រាន់សម្រាប់ដោះស្រាយលើបញ្ហារំលោភបំពានសិទ្ធិមនុស្សនានា និងបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ការបង្កើត"ស.ជ.ស.ម"ឯករាជ្យឲ្យស្របតាមគោលការណ៍ទីក្រុងប៉ារីសត្រូវតែធ្វើឡើងដើម្បីបំពេញតម្រូវការរបស់ប្រជាជនខ្មែរគ្រប់រូបដោយពិនិត្យមើលទៅលើបញ្ហាសិទ្ធិមនុស្សរបស់ពួកគេ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org ឬកញ្ញា សាណា ហ្គោស តាមរយៈលេខ (៨៥៥) ៨៩ ៦១ ៤៣ ៣៥ ឬតាមរយៈអ៊ីមែល sana.ghouse@cchrcambodia.org។